**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសុខាភិបាល

មន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិន ព្រះកុសុមៈ
CAMBODIA-CHINA FRIENGSHIP PREAH KOSSAMAK HOSPITAL
គណៈកម្មាធិការលទ្ធកម្ម
លេខ.០០៧/១៨.៧......ម.ព.ក.ច.ក

# សេចក្តីជូនដំណឹង
## ស្តីពីការអញ្ជើញចូលរួមដេញថ្លៃ
## ការបោះពុម្ពឯកសារអ្នកជម្ងឺ
## ជូនមន្ទីរពេទ្យព្រះកុសុមៈ

មន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិន ព្រះកុសុមៈ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស ( គិតទាំងសហគ្រាសឯកត្តបុគ្គល ) ទាំងអស់ដែលបានចុះ បញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា មន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិន ព្រះកុសុមៈនឹងដាក់ឲ្យដេញថ្លៃជាសាធារណៈ ដើម្បីបោះពុម្ពឯកសារអ្នកជម្ងឺ ។

មន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិន ព្រះកុសុមៈ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញ ដើម្បីចូលរួមដេញថ្លៃ ។ ឯកសារដេញថ្លៃមានដាក់លក់នៅអង្គភាពលទ្ធកម្មមន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិន ព្រះកុសុមៈ ដែលមានអាសយដ្ឋាន ជីឡូតិ៍លេខៈ១៨៨ ផ្លូវលេខៈ២៧១សង្កាត់ ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញចាប់ពីថ្ងៃ...ព្រ ៤រោច......ខែ...ពិសាខ......ឆ្នាំ...ច សំរឹទ្ធិស័ក... ព.ស២៥៦២.ត្រូវនឹងថ្ងៃទី......០៣......ខែ.ឧសភា...ឆ្នាំ២០១៨. តទៅ រៀងរាល់ម៉ោងធ្វើការ(ទូរស័ព្ទទំនាក់ទំនងលេខៈ...070 884 383 ...................... ។ ប្រាក់ទិញឯកសារដេញថ្លៃ មិនអាចបង្វិលជូនវិញបានឡើយ ។

ឯកសារដេញថ្លៃដែលបានបំពេញរួចត្រូវប្រគល់ជូនអង្គភាពលទ្ធកម្មយ៉ាងយូរបំផុតត្រឹមថ្ងៃ...ច័ន្ទ ១កើត.........................ខែ...... ជេស្ឋ......ឆ្នាំ...ច សំរឹទ្ធិស័ក......ព.ស២៥៦២..ត្រូវនឹងថ្ងៃទី.....០៣.........ខែ..មិថុនា.....ឆ្នាំ២០១៨..។ រាល់សំណើដេញថ្លៃដែលដាក់ក្រោយកាលបរិច្ឆេទកំណត់ នឹងត្រូវបដិសេធ ។

សំណើដេញថ្លៃនឹងត្រូវបើកជាសាធារណៈ ដោយមានការចូលរួមពីតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋាន លទ្ធកម្មសាធារណៈ) នៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ និងត្រូវបើកនៅថ្ងៃ...ច័ន្ទ ១កើត..............ខែ.....ជេស្ឋ.......ឆ្នាំ...ច សំរឹទ្ធិស័ក ព.ស ២៥៦២.. ត្រូវនឹងថ្ងៃទី.....០៣...........ខែ.....មិថុនា..............ឆ្នាំ២០១៨ វេលាម៉ោង..9:30...........នាទីជាកំហិត និង ដោយមានវត្តមានចូលរួមពីក្រុមហ៊ុនផ្គត់ផ្គង់ ឬតំណាងស្របច្បាប់ ។

សំណើដេញថ្លៃ ត្រូវភ្ជាប់មកជាមួយនូវលិខិតធានាប្រាក់កក់ធានាការដេញថ្លៃ ចំនួន២ភាគរយ ចេញដោយអគ្គនាយកដ្ឋាន រតនាគារជាតិ ឬធនាគារពាណិជ្ជដៃគូ ដូចមានរៀបរាប់នៅក្នុងសេចក្តីណែនាំចំពោះអ្នកដេញថ្លៃ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬ មានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃ..ព្រ ៤រោច.........ខែ....ពិសាខ......ឆ្នាំ...ច សំរឹទ្ធិស័ក. ព.ស.២៥៦២
រាជធានីភ្នំពេញថ្ងៃទី......០៣.........ខែ...ឧសភា......ឆ្នាំ២០១៨

**នាយកមន្ទីរពេទ្យ និងជា**
**ប្រធានគណៈកម្មាធិការលទ្ធកម្ម(គ.ល)**

ចំលងជូនៈ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
« អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ»
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ-កាលប្បវត្តិ

**ប្រូហ្វេសឺរ គាត់ សុគន**